**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

## សារលិខិតថ្វាយព្រះពរ

**សូមក្រាបបង្គំទូលថ្វាយ**
**សម្ដេចព្រះមហាក្សត្រ នរោត្តម សីហនុ**
**ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្ដីថ្លៃថ្នូរ និងសុភមង្គល**

**សម្ដេចព្រះមហាក្សត្រ ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈ ដ៏ខ្ពង់ខ្ពស់បំផុត !**

ក្នុងឱកាសដ៏នក្ខត្តឫក្សបវរថ្លៃថ្លា នៃព្រះរាជពិធីបុណ្យចម្រើនព្រះជន្មគម្រប់ ៨៥ យាងចូល ៨៦ ព្រះវស្សានា ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២១នេះ ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ក្នុងនាមទូលព្រះបង្គំនិងភរិយា ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហាន នៃកងយោធពលខេមរភូមិន្ទ សូមលំឱនកាយវាចាចិត្តក្រាបបង្គំទូលថ្វាយ នូវព្រះសព្ទសាធុការពរជ័យ បវរសួស្ដី សិរីមង្គល វិបុលសុខ មហាប្រសើរថ្វាយ **សម្ដេចព្រះមហាក្សត្រ ព្រះវររាជមាតាជាតិខ្មែរ** សូមទ្រង់ប្រកបដោយព្រះរាជសុខភាពល្អបរិបូរណ៍ ព្រះកាយពលរឹងមាំ ព្រះជន្មាយុយឺនយូរ ដើម្បីទ្រង់គង់នៅជាម្លប់ដ៏ត្រជាក់ត្រជុំដល់ប្រជារាស្ត្រជាកូនចៅចៅទួតរបស់ព្រះអង្គជានិច្ចនិរន្តរ៍តរៀងទៅ។

ទូលព្រះបង្គំជាកូន ចៅ ចៅទួតទាំងអស់គ្នា សូមព្រះបរមរាជានុញ្ញាតគោរពកោតសរសើរ គោរពស្ញប់ស្ញែង និងចងចាំជានិច្ចចំពោះព្រះរាជស្នាព្រះហស្តដ៏ឧត្តុង្គឧត្តមរបស់ **សម្ដេចព្រះមហាក្សត្រ ព្រះវររាជមាតាជាតិខ្មែរ** ក្នុងការបម្រើជាតិ សាសនា និងប្រជារាស្ត្រតាមរយៈព្រះរាជសកម្មភាពមនុស្សធម៌ លើកកម្ពស់កិត្តិយស និងសេចក្ដីថ្លៃថ្នូររបស់ស្ត្រី និងវិស័យសង្គមកិច្ចជាដើម ព្រះរាជគុណូបការៈដ៏ឧត្តុង្គឧត្តមរបស់ព្រះអង្គ មានតម្លៃមហាសែនថ្លៃថ្លាពុំអាចកាត់ថ្លៃបានឡើយ។

ជាថ្មីម្ដងទៀត ក្នុងឱកាសដ៏មហាសិរីមង្គលនេះ ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា សូមលំឱនកាយវាចាចិត្តបួងសួងចំពោះគុណបុណ្យព្រះរតនត្រ័យ វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក ទេវតារក្សាព្រះមហាស្វេតច្ឆត្រ ទេវតាឆ្នាំថ្មីនិងបារមីនៃអតីតព្រះមហាក្សត្រ មហាក្សត្រីយានីខ្មែរគ្រប់ព្រះអង្គ សូមទ្រង់ព្រះមេត្តាប្រោះព្រំសព្ទសាធុការពរជ័យ សិរីមង្គល វិបុលសុខ មហាប្រសើរ ថ្វាយ **សម្ដេចព្រះមហាក្សត្រ ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈ សូមព្រះអង្គប្រកបដោយ ព្រះរាជសុខភាពល្អបរិបូរណ៍ ព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា ដើម្បីទ្រង់គង់នៅជាមួយទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នាជាកូន ចៅ ចៅទួតរបស់ព្រះអង្គជានិច្ចនិរន្តរ៍តរៀងទៅ។

សូម **សម្ដេចព្រះមហាក្សត្រ នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្ដីថ្លៃថ្នូរ និងសុភមង្គល** ជាទីគោរពសក្ការៈ ទ្រង់ព្រះមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា។

សេចក្ដីគួរពុំគួរសូមទ្រង់ព្រះមេត្តាប្រោស។

ថ្ងៃ សុក្រ ៩ កើត ខែ បឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
សូមក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២១
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

សម្ដេចពិជ័យសេនា **ទៀ បាញ់**